# មេរៀនទី ៨៣៖ បញ្ញត្តិទាំង ១០ប្រការ (ភាគ២)

## និក្ខមនំ ១៩:១៦-២០:២១

**មេរៀន** *(យូធូបលីង)*៖ https://youtu.be/dDvEn9zrgkY

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/CDxG_kKnNRA

**គោលបំណង៖ ព្រះចង់ឲ្យយើងគោរពអ្នកដទៃ**

**ខគម្ពីរចងចាំ៖ ចោទិយកថា ៦:៦** *"សេចក្តីទាំងនេះដែលអញបង្គាប់ដល់ឯងនៅថ្ងៃនេះ នោះត្រូវនៅជាប់ក្នុងចិត្តឯងចុះ"។*

**ចំរៀង** *(យូធូបលីង)*៖

១. ខ្ញុំឲ្យបញ្ញត្តិមួយថ្មី https://youtu.be/lio2oGzBFz8

២. ចូរបន្ទាបខ្លួននៅចំពោះព្រះអង្គ https://youtu.be/7WO74xMesGU

៣. គឺជាការល្អ https://youtu.be/Z91SULEHfho

### ១. អធិស្ឋាន

### ២. ចំរៀង *សូមច្រៀងចម្រៀងដែលមាន link នៅក្នុងយូធូបខាងលើ*

### ៣. ល្បែងកំសាន្ត "ស្វែងរកកំណប់"



១. សូមកាត់ក្រដាសនៃក្រឹត្យវិន័យ១០ប្រការចេញពីគ្នា (មាននៅទំព័រខាងក្រោម) ដាក់វាចូលនៅក្នុង ប្រអប់មួយ ហើយយកវាទៅលាក់នៅកន្លែងណាមួយក្នុងថ្នាក់រៀន។

២. ឲ្យកុមារទាំងអស់ដើររកប្រអប់កំណប់នោះ

៣. នៅពេលដែលកុមាររក "កំណប់" នោះឃើញហើយ សូមឲ្យកុមារអាន បញ្ញត្តិនីមួយៗតាមលំដាប់លំដោយ។

### ៤. ការណែនាំមេរៀន

ពេលដែលយើងស្រឡាញ់អ្នកណាម្នាក់ យើងចង់ធ្វើឲ្យអ្នកនោះសប្បាយចិត្ត គឺមានន័យថាយើងចង់ធ្វើអ្វីដែលម្នាក់នោះចង់ឲ្យយើងធ្វើ។ ប្រសិនបើប្អូនស្រឡាញ់ម្តាយរបស់ប្អូន ប្អូនចង់ធ្វើឲ្យគាត់សប្បាយចិត្តដោយស្តាប់បង្គាប់គាត់។ ប្រសិនបើប្អូនស្រឡាញ់មិត្តភក្តិរបស់ប្អូន ប្អូនចង់ធ្វើឲ្យពួកគេសប្បាយចិត្តដោយការធ្វើល្អដាក់ពួកគេ។ ប្រសិនបើប្អូនស្រឡាញ់ព្រះ ប្អូនក៏ចង់ធ្វើឲ្យព្រះសប្បាយព្រះទ័យដែរ។ តើប្អូនអាច ធ្វើអ្វីបានខ្លះដើម្បីឲ្យព្រះសប្បាយព្រះទ័យ? ថ្ងៃនេះយើងនឹងរៀនពីការគោរពអ្នកដទៃដើម្បីធ្វើឲ្យព្រះសប្បាយព្រះទ័យ។

### ៥. រឿងនៅក្នុងព្រះគម្ពីរ

បញ្ញត្តិទាំង១០ប្រការប្រាប់យើងពីរបៀបដែលធ្វើឲ្យព្រះសប្បាយព្រះទ័យ ដោយការស្រឡាញ់ព្រះអង្គ និងប្រព្រឹត្តជាមួយអ្នកដទៃដោយការគោរព។ ឲ្យកុមារទាំងអស់សូត្របញ្ញត្តិទាំង ៤ប្រការឡើងវិញ ថ្ងៃនេះយើងនិងរៀនបញ្ញត្តិ៦ប្រការទៀត។ នៅក្នុងល្បែងនេះ គ្រូនឹងសួរកុមារ ហើយកុមារនិងឆ្លើយសំនួរ ទាំងអស់នោះ។ ពេលខ្លះចំលើយអាចជា "ពីព្រោះអង្គបានមានបន្ទូលដូច្នេះ ទើបយើងត្រូវស្រឡាញ់ទ្រង់" ។

**បញ្ញត្តិទី៥៖ និក្ខមនំ ២០៖១២** *"ចូរឲ្យគោរពប្រតិបត្តិដល់ឪពុកម្តាយ ដើម្បីឲ្យបានអាយុវែងនៅក្នុង ស្រុកដែលព្រះយេហូវ៉ាជាព្រះនៃឯងទ្រង់ប្រទានឲ្យ។"*

ប្រសិនបើម្តាយរបស់ខ្ញុំប្រាប់ខ្ញុំមិនឲ្យញុំស្ករគ្រាប់ នេះមុនញុំាបាយថ្ងៃត្រង់ទេ តើខ្ញុំគួរតែញុំាវាដែរឬទេ?

**ក.**តើខ្ញុំដឹងដោយរបៀបណាថាខ្ញុំគួរធ្វើតាមនូវអ្វីដែលម៉ាក់ខ្ញុំនិយាយ? សូមឲ្យកុមារក្រោកឈរ ហើយស្រែកថា "ពីព្រោះព្រះប្រាប់ឲ្យយើងធ្វើបែបនេះ ហើយយើងស្រលាញ់ព្រះ" ។

**ខ.**ត្រឹមត្រូវហើយ បញ្ញត្តិ១ក្នុងចំណោមបញ្ញត្តិទាំង១០និយាយថា **"ប្អូនៗត្រូវគោរពឪពុកម្តាយរបស់ប្អូន"** ដែលមានន័យថាប្អូនត្រូវតែស្តាប់បង្គាប់ ហើយគោរពពួកគាត់។

**បញ្ញត្តិទី៦៖ និក្ខមនំ ២០៖១៣** *"កុំឲ្យសំឡាប់មនុស្សឲ្យសោះ។"*

បើសិនអ្នកណាម្នាក់មានស្ករគ្រាប់ តើខ្ញុំគួរតែធ្វើបាបអ្នកនោះ ដើម្បីឲ្យខ្ញុំអាចយកស្ករគ្រាប់នោះបានឬយ៉ាងណា?

**ក.** តើខ្ញុំដឹងដោយរបៀបណាថាខ្ញុំមិនគួរធ្វើឲ្យអ្នកដទៃឈឺចាប់? សូមឲ្យកុមារក្រោកឈរ ហើយស្រែកថា *"ពីព្រោះព្រះប្រាប់ឲ្យយើងធ្វើបែបនេះ ហើយយើងស្រលាញ់ព្រះ។"*

**ខ.**ត្រឹមត្រូវហើយ ក្នុងបញ្ញត្តិទាំង១០ប្រការបានប្រាប់ខ្ញុំថា វាជារឿងមិនត្រឹមត្រូវនោះទេ ក្នុងការសំលាប់នរណាម្នាក់។ **ព្រះស្រឡាញ់មនុស្សលោកទាំងអស់ ហើយទ្រង់ចង់ឲ្យយើងស្រលាញ់មនុស្សទាំងនោះដែរ ហើយកុំធ្វើឲ្យពួកគេឈឺចាប់ផងដែរ។**

**បញ្ញត្តិទី៧៖ និក្ខមនំ ២០៖១៤** *"កុំឲ្យផិតគ្នាឲ្យសោះ។"*

ឪពុករបស់ខ្ញុំមិនចូលចិត្តស្ករគ្រាប់ទេ គាត់គ្មានស្ករគ្រាប់សូម្បីតែ១គ្រាប់។ ប៉ុន្តែម្តាយខ្ញុំចូលចិត្តស្ករគ្រាប់ណាស់ ហើយមិត្តភក្តិរបស់ប៉ាខ្ញុំចូលចិត្តស្ករគ្រាប់ ហើយគាត់មានស្ករគ្រាប់ច្រើនណាស់ តើម្តាយរបស់ខ្ញុំគួរតែទៅតាមមិត្តភក្តិរបស់ប៉ាខ្ញុំដែរឬទេ?

**ក.**តើខ្ញុំដឹងដោយរបៀបណាថាខ្ញុំមិនគួររត់តាមប្តី ឬប្រពន្ធរបស់អ្នកណាម្នាក់នោះ? សូមឲ្យកុមារក្រោកឈរ ហើយស្រែកនិយាយថា *"ពីព្រោះព្រះមានបន្ទូលដូច្នេះ ហើយយើងស្រឡាញ់ព្រះអង្គ"* ។

ខ. ត្រឹមត្រូវហើយ នៅក្នុងបញ្ញត្តិទាំង១០ ព្រះបានប្រាប់យើងថាយើងមិនត្រូវរត់តាមប្តី ឬប្រពន្ធរបស់អ្នកដទៃឡើយ។ **ព្រះចង់ឲ្យមនុស្សទាំងអស់ស្រលាញ់ប្តី ឬប្រពន្ធរបស់ខ្លួន ហើយឲ្យរស់នៅជាមួយគ្នា**។

**បញ្ញត្តិទី៨៖ និក្ខមនំ ២០៖១៥** *"កុំឲ្យលួចប្លន់ឲ្យសោះ។"*

បើសិនជាខ្ញុំដាក់ស្ករគ្រាប់នៅលើតុ ហើយដើរចេញទៅ តើប្អូននឹងលួចវាដែរឬទេ?

**ក.** តើប្អូនដឹងដោយរបៀបណាថាប្អូនមិនគួរលួចរបស់អ្នកដទៃ? សូមឲ្យកុមារក្រោកឈរ ហើយស្រែកថា *"ពីព្រោះព្រះមានបន្ទូលដូច្នេះ ហើយយើងស្រឡាញ់ព្រះអង្គ"*

**ខ.** ត្រឹមត្រូវហើយ នៅក្នុងបញ្ញត្តិទាំង១០ប្រការ **ព្រះប្រាប់យើងថាមិនត្រូវលួចឡើយ**។ យើងចង់ធ្វើឲ្យព្រះសប្បាយព្រះទ័យដោយការធ្វើតាមបញ្ញត្តិរបស់ទ្រង់។

**បញ្ញត្តិទី៩៖ និក្ខមនំ ២០៖១៦** *"កុំឲ្យធ្វើជាទីបន្ទាល់ក្លែង ទាស់នឹងអ្នកជិតខាងខ្លួនឲ្យសោះ។"*

(គ្រូយកស្ករគ្រាប់ដាក់នៅក្នុងហោប៉ៅ ឬកាបូបរបស់ខ្លួន) ហើយគ្រូស្រែកសួរថាតើអ្នកណាបានយកស្ករគ្រាប់នោះ? តើត្រឹមត្រូវដែរឬទេបើយើងនិយាយថាអ្នកដទៃបានយកស្ករគ្រាប់នោះ?

**ក.** តើខ្ញុំដឹងដោយរបៀបណាថាខ្ញុំមិនគួរកុហកនោះទេ? សូមឲ្យកុមារម្នាក់ក្រោកឈរ ហើយស្រែកថា *"ពីព្រោះព្រះមានបន្ទូលដូច្នេះ ហើយយើងស្រឡាញ់ព្រះអង្គ"*

ខ. ត្រឹមត្រូវហើយនៅក្នុងបញ្ញត្តិទាំង១០ប្រការ ព្រះបានប្រាប់យើងថាមិនត្រូវកុហកឡើយ។ ពេលដែលយើងនិយាយការពិត យើងធ្វើឲ្យព្រះសប្បាយព្រះទ័យ ពីព្រោះយើងធ្វើតាមបញ្ញត្តិ របស់ព្រះអង្គ។

**បញ្ញត្តិទី១០៖ និក្ខមនំ ២០៖១៧** *"កុំឲ្យលោភចង់បានផ្ទះអ្នកជិតខាងខ្លួនឲ្យសោះ"*

បើសិនជាអ្នកដ៏ទៃមានស្គរគ្រាប់ ហើយខ្ញុំអត់មាន តើវាត្រឹមត្រូវទេដែរឬទេ ដែលខ្ញុំគិតថាខ្ញុំក៏ចង់បានស្គរគ្រាប់ដែរនោះ? (ក្រោកឡើងហើយដើរជុំវិញបន្ទប់ដោយស្រែកខ្លាំងៗថាអ្នកចង់បាន ស្គរគ្រាប់នេះខ្លាំងប៉ុនណា)។ ការដែលយើងចង់បានខ្លាំងហួសហេតុបែបនេះគឺមានន័យថាជា ការលោភលន់។ មានន័យថាប្អូនចង់បានអ្វីដែលជារបស់អ្នកដ៏ទៃមកធ្វើជារបស់ខ្លួនឯង។ ហើយប្អូនមិនចង់ឲ្យអ្នកដទៃមានរបស់នោះទេ។ ប្អូនចង់មានរបស់នោះសំរាប់ខ្លួនឯងតែប៉ុណ្ណោះ។

**ក.**តើខ្ញុំដឹងដោយរបៀបណាថា ខ្ញុំមិនគួរលោភលន់ចង់បានស្គរគ្រាប់នោះតែម្នាក់ឯងនោះទេ? សូមឲ្យកុមារស្រែកឃ្លារបស់ពួកគេ(ដែលបានឆ្លើយ)។

ខ. ត្រឹមត្រូវហើយ នៅក្នុងបញ្ញត្តិទាំង១០ប្រការ **ព្រះបានប្រាប់យើងថាកុំប្រាថ្នាភាពលោភលន់ ចង់បានរបស់អ្នកដទៃ។**

នៅពេលដែលយើងបានប្រព្រឹត្តជាមួយអ្នកដទៃតាមផ្លូវដែលព្រះចង់ឲ្យយើងប្រព្រឹត្តជាមួយពួកគេ តាមបញ្ញត្តិទាំង១០ប្រការ គឺយើងកំពុងតែធ្វើឲ្យព្រះសប្បាយព្រះទ័យហើយ។

## ៦.សំនួរពិភាក្សា

១. តើបញ្ញត្តិទាំង៦ដែលយើងបានរៀននៅថ្ងៃនេះគឺអ្វីខ្លះ?(*គោរពឪពុកម្តាយ កុំឲ្យសំលាប់ឡើយ (កុំធ្វើឲ្យអ្នកដទៃឈឺចាប់)ប្តីនិងប្រពន្ធរស់នៅជុំគ្នា កុំឲ្យលួចឲ្យសោះ កុំឲ្យកុហកឲ្យសោះ កុំឲ្យលោភលន់ឲ្យសោះ*)។

២. តើប្អូនអាចធ្វើអ្វីខ្លះដើម្បីបង្ហាញថាជាការគោរពទៅកាន់ព្រះ និងអ្នកដទៃ?

(*ធ្វើតាមបញ្ញត្តិទាំង១០ប្រការ ហើយធ្វើល្អទៅកាន់អ្នកដទៃ*)

## ៧.ល្បែងកំសាន្ត « តើប្អូនអាចចាំដែរឬទេ?»



១.ចែកកុមារជាក្រុម មួយក្រុមមានគ្នា ៣-៤នាក់ ហើយឲ្យក្រដាសបន្ទះថ្មដែលគ្រូបានបោះពុម្ព ហើយឲ្យទៅកុមារ (*មើលទំព័រខាងក្រោម*)

២. ឲ្យកុមារសរសេរពីបញ្ញត្តិទាំង១០ប្រការឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។

## ៨. ខគម្ពីរចងចាំ

**ចោទិយកថា ៦៖៦** *" សេចក្តីទាំងនេះដែលអញបង្គាប់ដល់ឯងនៅថ្ងៃនេះ នោះត្រូវនៅជាប់ ក្នុងចិត្តឯងចុះ។"*




## ៩. ហាត្ថកម្ម(ជំរើសទី១)

១. ឲ្យបន្ទះឈើការ៉េមទៅកុមារម្នាក់ៗ ហើយឲ្យកុមារសរសេរបញ្ញត្តិទាំង ១០ ប្រការ លើបន្ទះឈើនោះ។

២. ឲ្យខ្សែ និងកាវទៅកុមារដើម្បីបិតដូច្នេះកុមារអាចនឹងចងព្យួរ បញ្ញត្តិនោះ បាន។

(**ជំរើសទី២**)៖ ឲ្យកុមារផាត់ពណ៌នៅលើទំព័របញ្ញត្តិទាំង១០ប្រការ

## ១០. ចំរៀង (រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ ( សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន )**
ពេលដែលទំនាក់ទំនងរបស់យើងជាមួយព្រះយេស៊ូវមានការលូតលាស់ យើងអាចចាប់ផ្តើមមើលឃើញពិភពលោក និងមនុស្សផ្សេងទៀតតាមរយៈកែវភ្នែកនៃក្តីស្រឡាញ់ដោយឥតលក្ខខណ្ឌ។ យើងនឹងមានអំណរ នៅក្នុងការប្រកបគ្នាបន្ថែមទៀត ហើយអ្នកផ្សេងនឹងមើលឃើញវត្តមានព្រះយេស៊ូវតាមរយៈជីវិតរបស់យើង។ មនុស្សគ្រប់រូបដែលអ្នកមានទំនាក់ទំនងជាមួយអ្នកនៅថ្ងៃនេះផ្តល់ឲ្យអ្នកនូវឱកាសដើម្បីបង្ហាញសិរីរុងរឿងរបស់ព្រះដោយការលើកបង្ហាញពីការបង្កើតដ៏អស្ចារ្យរបស់ទ្រង់ទៅកាន់ពួកគេ។ តើអ្នកនឹងអនុញ្ញាតឲ្យព្រះប្រទានពរដល់អ្នកណានៅថ្ងៃនេះតាមរយៈទង្វើរបស់អ្នក? ដល់មនុស្សគ្រប់គ្នាឬ? បុគ្គលដែលឆ្លងកាត់ពេលវេលាដ៏លំបាកជាច្រើនឬ? សូមចំណាយពេលយកចិត្តទុកដាក់ជាមួយមនុស្សដែលអ្នកជួបនៅថ្ងៃនេះ ហើយមើលពីរបៀបដែលអ្នកអាចនាំយកព្រះពរទៅកាន់ពួកគេបាន?

| **ល្បែងកំសាន្ត “ស្វែងរកកំណប់”**<br>សូមកាត់ បញ្ញាតិទាំង១០ប្រការ ហើយយកទៅដាក់ក្នុងប្រអប់កំណប់ |
|---|
| ១. កុំឲ្យមានព្រះឯណាទៀតនៅចំពោះអញឲ្យសោះ |
| ២. កុំថ្វាយបង្គំរូបព្រះឲ្យសោះ |
| ៣.សូមប្រុងប្រយត្ន័ក្នុងការប្រើព្រះនាមព្រះ |
| ៤. សូមរក្សាថ្ងៃបរិសុទ្ធរបស់ព្រះជាថ្ងៃពិសេស |
| ៥. គោរពប្រតិបត្តឪពុកម្តាយរបស់អ្នក |
| ៦. កុំសម្លាប់មនុស្សឲ្យសោះ |
| ៧. កុំឲ្យផិតគ្នាឲ្យសោះ |
| ៨. កុំលួចឲ្យសោះ |
| ៩. កុំកុហកឲ្យសោះ |
| ១០. កុំលោភលន់ឲ្យសោះ |



# បញ្ញត្តិទាំង ១០ប្រការ



សូមសរសេរខគម្ពីរចងចាំ: ______________________________

______________________________________________________

______________________________________________________

______________________________________________________